ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ :.....០០៦/២២.....ក.ប/ស.ជ.ណ.ខ.ល

## សេចក្តីជូនដំណឹង

## ស្តីពី

## ការចុះធ្វើជំរឿនសេដ្ឋកិច្ចនៅតាមបណ្តារោងចក្រ សហគ្រាស នៅទូទាំងប្រទេស របស់មន្ត្រីជំរឿននៃក្រសួងផែនការ

យោងលិខិតលេខ ០០៣៥ ផក. ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ របស់ក្រសួងផែនការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ ឬនាយករោងចក្រ សហគ្រាសទាំងអស់ មេត្តាជ្រាបថា ដើម្បីប្រមូលទិន្នន័យព័ត៌មានបច្ចុប្បន្នភាពអំពីស្ថានភាពសេដ្ឋកិច្ចកម្ពុជាគ្រប់វិស័យ (ឧស្សាហកម្ម និងសេវាកម្ម) សមភាពយេនឌ័រ លក្ខណៈនៃប្រភេទអាជីវកម្ម ស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាព សេដ្ឋកិច្ច ចំនួនសហគ្រាស (ខ្នាតមីក្រូ តូច មធ្យម និងខ្នាតធំ) ចំនួនកម្លាំងពលកម្ម (កម្មករនិយោជិត) និងព័ត៌មានផ្សេងៗទៀត ក្រសួងផែនការនឹងចាត់មន្ត្រីជំរឿនចុះសម្ភាសន៍ និងកត់ត្រាទិន្នន័យស្ថិតិនៅតាមរោងចក្រ សហគ្រាសទាំងអស់ នៅតាមមូលដ្ឋានភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ រាជធានី ខេត្ត ទាំង២៥ ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ រហូតដល់ចប់ជាស្ថាពរ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង **លោក ទេព ស័ក្តមករា ០១១ ៦៦២ ៧១៣។**

ក្រសួងមានសេចក្តីជឿជាក់ថា ម្ចាស់ ឬនាយករោងចក្រ សហគ្រាសទាំងអស់ នឹងផ្តល់កិច្ចសហការសម្របសម្រួលដល់មន្ត្រីជំរឿនរបស់ក្រសួងផែនការ ក្នុងការសម្ភាស និងកត់ត្រាទិន្នន័យស្ថិតិនៅតាមរោងចក្រ សហគ្រាស ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍៨រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន:**

- ក្រសួងផែនការ
- រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩